ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំ ២០,៧៨ ហិកតា នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីដីតំបន់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិ ជូនប្រជាពលរដ្ឋ ៣៧គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ



www.pheakdeylaw.com

- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៦៤អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីទំហំ ២០,៧៨ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ២០,៤៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ០,២៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិកោះឈើទាល ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៧គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិកោះឈើទាល ឃុំទួលសាលា ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៥៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីទំហំ ២០,៧៨ហិកតា នៅក្នុងស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ៣៧គ្រួសារ និងក្បាលដីមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




តារាងចំណុចនិយាមកា

| ID | X | Y | ID | X | Y | ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 449730 | 1245590 | 22 | 449407 | 1245986 | 43 | 448821 | 1245570 | 63 | 449183 | 1245456 | 83 | 449161 | 1245721 |
| 2 | 449733 | 1245606 | 23 | 449392 | 1245968 | 44 | 448893 | 1245494 | 64 | 449208 | 1245459 | 84 | 449234 | 1245730 |
| 3 | 449710 | 1245614 | 24 | 449344 | 1245942 | 45 | 448908 | 1245480 | 65 | 449201 | 1245498 | 85 | 449232 | 1245749 |
| 4 | 449710 | 1245624 | 25 | 449315 | 1245918 | 46 | 448965 | 1245427 | 66 | 449223 | 1245494 | 86 | 449242 | 1245751 |
| 5 | 449733 | 1245736 | 26 | 449245 | 1245895 | 47 | 448971 | 1245410 | 67 | 449222 | 1245525 | 87 | 449242 | 1245770 |
| 6 | 449733 | 1245737 | 27 | 449204 | 1245911 | 48 | 448981 | 1245395 | 68 | 449223 | 1245528 | 88 | 449228 | 1245773 |
| 7 | 449731 | 1245751 | 28 | 449124 | 1245914 | 49 | 448982 | 1245406 | 69 | 449238 | 1245527 | 89 | 449229 | 1245815 |
| 8 | 449733 | 1245787 | 29 | 449125 | 1245932 | 50 | 449036 | 1245401 | 70 | 449240 | 1245556 | 90 | 449303 | 1245808 |
| 9 | 449731 | 1245839 | 30 | 449012 | 1245928 | 51 | 449036 | 1245392 | 71 | 449233 | 1245594 | 91 | 449338 | 1245805 |
| 10 | 449718 | 1245951 | 31 | 449009 | 1245874 | 52 | 449067 | 1245389 | 72 | 449223 | 1245599 | 92 | 449379 | 1245796 |
| 11 | 449703 | 1245965 | 32 | 449046 | 1245804 | 53 | 449099 | 1245390 | 73 | 449242 | 1245600 | 93 | 449379 | 1245810 |
| 12 | 449712 | 1245988 | 33 | 449049 | 1245747 | 54 | 449101 | 1245409 | 74 | 449239 | 1245610 | 94 | 449492 | 1245773 |
| 13 | 449666 | 1245998 | 34 | 449061 | 1245692 | 55 | 449125 | 1245411 | 75 | 449229 | 1245640 | 95 | 449491 | 1245733 |
| 14 | 449658 | 1245980 | 35 | 449076 | 1245647 | 56 | 449118 | 1245461 | 76 | 449214 | 1245633 | 96 | 449539 | 1245720 |
| 15 | 449631 | 1245988 | 36 | 449144 | 1245618 | 57 | 449133 | 1245463 | 77 | 449215 | 1245622 | 97 | 449567 | 1245711 |
| 16 | 449597 | 1245991 | 37 | 449200 | 1245529 | 58 | 449141 | 1245434 | 78 | 449208 | 1245614 | 98 | 449570 | 1245729 |
| 17 | 449597 | 1245978 | 38 | 449102 | 1245495 | 59 | 449157 | 1245434 | 79 | 449203 | 1245613 | 99 | 449639 | 1245706 |
| 18 | 449572 | 1245982 | 39 | 449026 | 1245525 | 60 | 449155 | 1245441 | 80 | 449185 | 1245628 | 100 | 449635 | 1245689 |
| 19 | 449527 | 1245984 | 40 | 448875 | 1245569 | 61 | 449166 | 1245443 | 81 | 449171 | 1245678 | 101 | 449656 | 1245684 |
| 20 | 449522 | 1246038 | 41 | 448811 | 1245607 | 62 | 449180 | 1245441 | 82 | 449165 | 1245697 | 102 | 449645 | 1245600 |
| 21 | 449446 | 1246074 | 42 | 448810 | 1245590 | | | | | | | | | |